**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ១៧១៣ ព.ណ.ន.ឆ.ពកធ

ថ្ងៃចន្ទ ៩ កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាពាណិជ្ជករ និងសាធារណជនទូទៅឱ្យបានជ្រាបថា សាធារណរដ្ឋអាល់ហ្សេរី នឹងរៀបចំ **«ពិព័រណ៍អន្តរជាតិអាល់ហ្សេលើកទី៥៧** (The 57th Algiers International Fair)**»** ពីថ្ងៃទី២២-២៧ ខែមិថុនា ឆ្នាំ២០២៦ នៅទីក្រុងអាល់ហ្សេ ប្រទេសអាល់ហ្សេរី។ ពិព័រណ៍នេះគឺជាព្រឹត្តិការណ៍សេដ្ឋកិច្ច និងពាណិជ្ជកម្មនៃប្រទេសអាល់ហ្សេរីប្រមូលផ្តុំដោយក្រុមហ៊ុនជាតិ និងអន្តរជាតិឈានមុខគ្រប់វិស័យ រួមមាន ពាណិជ្ជកម្ម សេវាកម្ម បច្ចេកវិទ្យា កសិ-ចំណីអាហារ និងថាមពល។ ព្រឹត្តិការណ៍នេះ នឹងផ្តល់នូវមូលដ្ឋានដ៏ទំនើប និងស៊ីជម្រៅសម្រាប់ការផ្លាស់ប្តូរធុរកិច្ច ដៃគូយុទ្ធសាស្ត្រ និងកាលានុវត្តភាពកំណើន។

ក្រសួងពាណិជ្ជកម្ម ក្នុងនាមអ្នកសម្របសម្រួលព្រឹត្តិការណ៍ខាងលើ សូមអញ្ជើញ លោក-លោកស្រី ដែលជាពាណិជ្ជករ និងសាធារណជន ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមពិព័រណ៍ខាងលើ សូមធ្វើការទំនាក់ទំនងចុះឈ្មោះចូលរួមតាមរយៈគេហទំព័រ៖ register.safex.dz។ សម្រាប់ព័ត៌មានបន្ថែម សូមធ្វើការទំនាក់ទំនងតាមរយៈអ៊ីម៉ែល៖ fia@safex.dz / event@safex.dz ឬ WhatsApp ៖+213 660 171 227។

**សូមអរគុណ!**

GO.gov.KH

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469